ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០១ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ /១២៤ ចុះ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ ០៤ នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញ ព្រះរាជក្រមលេខ ៦២ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញ ព្រះរាជក្រមលេខ នស / រកម/ ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧

# ស ម្រេ ច

**ប្រការ១:** បង្កើតក្រុមការងារអន្តរក្រសួង ដែលមានឈ្មោះថា « **ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ** » ដែលមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម **ខី តាឃី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
- ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាអនុប្រធាន
- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ២ រូប ជាសមាជិក
- តំណាងធនាគារជាតិ នៃកម្ពុជា ២ រូប ជាសមាជិក
- តំណាងនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ២ រូប ជាសមាជិក
- តំណាងនាយកដ្ឋានពន្ធដារ ១ រូប ជាសមាជិក
- តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ ១ រូប ជាសមាជិក
- ប្រធានការិយាល័យគ្រប់គ្រងអចលនវត្ថុ ជាសមាជិក និងជាលេខាធិការ

**ប្រការ២:** ក្រុមការងារអន្តរក្រសួងមានភារកិច្ចដូចតទៅ:

- រៀបចំតាក់តែងគោលនយោបាយអភិវឌ្ឍ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ។
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជូនរាជរដ្ឋាភិបាលអំពីការអភិវឌ្ឍន៍វិស័យអចលនវត្ថុ នៅព្រះរាជាណាចក្រកម្ពុជា ។
- ក្រុមការងារអន្តរក្រសួងអាចស្នើសុំរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បង្កើតក្រុមការងារតូចៗតាមការចាំបាច់ ។

**ប្រការ៣:** បន្ថែមលើមុខងារ និងភារកិច្ចដូចមានចែងក្នុងប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តិទៅ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ ទទួលតួនាទីជាលេខាធិការដ្ឋានអោយក្រុមការងារអន្តរក្រសួង ។

**ប្រការ៤:** សមាជិកទាំងអស់ត្រូវចូលរួមប្រជុំទៅតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥:** ក្នុងករណីប្រធានក្រុមការងារអវត្តមាន អនុប្រធានក្រុមការងារនេះធ្វើជាប្រធានស្តីទី ។

**ប្រការ៦:** ធនធាន និងថវិកាសំរាប់ចំណាយផ្សេងៗរបស់ក្រុមការងារនេះ ត្រូវបានផ្គត់ផ្គង់ដោយថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ/និងដោយចំណូលការប្រាក់ពីគណនីអាណត្តិ ព្យាបាលភាព ។

**ប្រការ៧:** ប្រធានក្រុមការងារត្រូវធ្វើរបាយការណ៍ប្រចាំឆមាសអំពីការអភិវឌ្ឍន៍វិស័យអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជា ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយចំលងជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងធនាគារជាតិនៃកម្ពុជា ។

**ប្រការ៨:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨*

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**<u>ចំលងជូន:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  « ដើម្បីជូនជ្រាប »
- ដូចមានក្នុងប្រការ ៨
  « ដើម្បីអនុវត្ត »
- ឯកសារ- កាលប្បវត្តិ